
នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ១៥៧ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការតែងតាំងមន្ត្រីរាជការ

****

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

ស ម្រេ ច

មាត្រា ១ : ត្រូវបានតែងតាំងលោក **សាម សាយ** ជាប្រធាននាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុ នៃក្រសួងអភិវឌ្ឍន៍ជនបទ ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ៣ ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ចម្លងជូន :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ - កាលប្បវត្តិ

40

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ......១៥៤......អនក្រ-តត

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

&&&&&&

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តសៀមរាប

ស ម្រ េ ច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនអ្នកស្ម័គ្រចិត្តជប៉ុន ចំនួន ១០ រូប ដែលបានខិតខំបង្កើតកម្មវិធី និង ជួសជុលផ្លូវលេខ ៦៨ ពីភូមិអូរស្មាច់ មកស្រុកក្រឡាញ់ ខេត្តសៀមរាប ចំណាយអស់ទឹកប្រាក់សរុបចំនួន ១៥.០០០.០០០ បាត ដូចមានរាយនាមខាងក្រោមនេះ ÷

១ - **Mr. Shin Yamato**

២ - **Mr. Kazuyuki Hirata**

៣ - **Mr. Takahisa Ishiko**

៤ - **Mr. Hiroyasu Konishi**

៥ - **Mr. Nobuyuki Arai**

៦ - **Mr. Takeshi Oka**

៧ - **Mr. Masami Seki**

៨ - **Mr. Masayoshi Saegusa**

៩ - **Mr. Ryoji Sano**

១០ - **Mr. Yong Yin**

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តសៀមរាប ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ

រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែ មីនា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៥៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

&&&&&&

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តសៀមរាប

ស ម្រេ ច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ជនជាតិអង់គ្លេស ០២ រូប ដែលបានចំណាយថវិកាផ្ទាល់ខ្លួនតាមរយៈអង្គការ រ៉េដបាណា ចំនួន ១០០.០០០ USD ជួយកសាងសាលារៀន ០៤ កន្លែង មាន ០៦ ខ្នង ចែកជា ១៩ បន្ទប់ នៅឃុំចារឈូក ឃុំដូនពែង និងឃុំគោកដូង ស្រុកអង្គរជុំ ខេត្តសៀមរាប ដូចមានរាយនាមខាងក្រោមនេះ ÷

១ - លោក MICHAEL YATES

២ - អ្នកស្រី INCRID YATES

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តសៀមរាប ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ០៥ សរណន

សារាចរណែនាំ

ស្តីពី

បំរាមធ្វើអាជីវកម្មជីករុករក និង បំផ្លាញវត្ថុបុរាណ

ទឹកដីនៃព្រះរាជាណាចក្រកម្ពុជាទាំងមូល ជាឃ្លាំងសម្បត្តិវប្បធម៌ ដែលសម្បូរបែបទៅដោយបុរាណវត្ថុនៅរាយប៉ាយទូទាំងប្រទេស រួមទាំងមហាប្រាសាទទាំងឡាយនៅលើដី និងវត្ថុបុរាណដែលកប់ក្នុងដី អស់កាលរាប់រយរាប់ពាន់ឆ្នាំ ដែលហៅថាកំណប់បុរាណវត្ថុរបស់បុព្វបុរសគ្រប់ជំនាន់ ។

សង្គ្រាមយូរអង្វែងទើបត្រូវបានបញ្ចប់ជាស្ថាពរបានធ្វើឱ្យវត្ថុបុរាណទាំងនោះខូចខាត បាត់បង់ និងមួយចំនួនធំត្រូវបានជនខិលខូចរួមគំនិតនឹងឈ្មួញបរទេសគាស់កកាយបំផ្លាញ លួចបញ្ជូនយកទៅលក់នៅទីផ្សារបរទេស ។ បច្ច័យទាំងនេះបានជះឥទ្ធិពលយ៉ាងខ្លាំងដល់ការថែរក្សា និងជីករុករកវត្ថុបុរាណ សំរាប់ការយល់ដឹង និងចងក្រងជាឯកសារសិក្សាស្រាវជ្រាវទៅអនាគត ។

ក្នុងបំណងរក្សាស្នាដៃជាប្រវត្តិសាស្ត្រមានជាអាទិ៍ ប្រាង្គប្រាសាទ និងវត្ថុបុរាណទាំងអស់ ដែលជាសម្បត្តិវប្បធម៌ជាតិទុកសំរាប់ការយល់ដឹងដល់អនុជនជំនាន់ក្រោយ រាជរដ្ឋាភិបាលយកចិត្តទុកដាក់ អភិរក្សរាល់មរតកប្រវត្តិសាស្ត្រទាំងអស់ ដែលនៅសេសសល់ក្រោយការបំផ្លាញដោយធម្មជាតិ សង្គ្រាម និងអាជីវកម្មខុសច្បាប់ ដោយពួកឈ្មួញទុច្ចរិត ដើម្បីភាពគង់វង្សនៃសម្បត្តិវប្បធម៌មនុស្សលោក,

រាជរដ្ឋាភិបាលសូមធ្វើការណែនាំដូចខាងក្រោម ៖

១_ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ អាជ្ញាធរអប្សរា សហការជាមួយអាជ្ញាធរដែនដីគ្រប់ខេត្ត-ក្រុងទាំងអស់ រួមជាមួយបន្ទីរជំនាញពាក់ព័ន្ធ នៅក្នុងមូលដ្ឋាននិមួយៗធ្វើការកំណត់ទីតាំងដែលសង្ស័យថាមានកំណប់វត្ថុបុរាណប្រវត្តិសាស្ត្រ រួចចាត់វិធានការថែរក្សាការពារ ដោយចុះក្នុងបញ្ជីសារពើភ័ណ្ឌរដ្ឋ និងបោះបង្គោលដែន ត្រូវការពារឱ្យបានត្រឹមត្រូវ ។

២_ហាមឃាត់នៅទូទាំងប្រទេស រាល់ការជីកកកាយនៅក្នុងដី ដើម្បីរាវរកវត្ថុបុរាណ ការសាងសង់ លើទីតាំងដែលមានសំណល់បុរាណវត្ថុ ឬជាអតីតសំណង់ប្រវត្តិសាស្ត្រ មានជាអាទិ៍ទីតាំង ប្រាសាទបាក់បែក ជំរុំស្នាក់នៅ

របស់មនុស្សសម័យដើម "រូងភ្នំ", ទីកន្លែងសាសនា "វត្ត ចេតិយ ដំបូកអ្នកតា ឬដើមពោធិ" ។ល។ លើកលែងតែការជីករុករកផ្នែកបុរាណវិទ្យា ដែលមានលក្ខណៈប្រវត្តិសាស្ត្រ និងវិទ្យាសាស្ត្រ ក្នុងបំណងសិក្សាស្រាវជ្រាវ ហើយមានការអនុញ្ញាតិស្របច្បាប់ពីរាជរដ្ឋាភិបាលជាមុនសិន ។

៣_ចំពោះមុខអាជ្ញាធរខេត្តគ្រប់ជាន់ថ្នាក់ ត្រូវសហការជាមួយនគរបាលបេតិកភ័ណ្ឌ មន្ទីរវប្បធម៌ខេត្ត និងកងកម្លាំងប្រដាប់អាវុធឈរជើងនៅនឹងកន្លែង ត្រូវចាត់វិធានការទប់ស្កាត់ជាបន្ទាន់ ចំពោះករណីគាស់បំផ្លាញ និងរុករកបុរាណវត្ថុដោយប្រជាជន និងឈ្មួញទុច្ចរិតមួយចំនួនតាមតំបន់ដូចខាងក្រោម ÷

- តំបន់បុរេប្រវត្តិសាស្ត្រភូមិស្នាយ និងភូមិថ្មី ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ
- តំបន់បុរេប្រវត្តិសាស្ត្រសម័យហ្វូណន នៅភ្នំដា ស្រុកអង្គរបុរី ខេត្តតាកែវ
- តំបន់បុរេប្រវត្តិសាស្ត្រមនុស្សសម័យដើមរស់នៅតាមគ្រប់ល្អាងភ្នំក្នុងខេត្តកំពត
- តំបន់ប្រាសាទសំបូរព្រៃគុក ស្រុកសំបូរ ខេត្តកំពង់ធំ
- តំបន់ប្រាសាទព្រះខ័នកំពង់ស្វាយ ខេត្តព្រះវិហារ
- តំបន់ភូមិមូល នៅចំការកៅស៊ូក្រែក-មេមត់ ក្នុងខេត្តកំពង់ចាម
- តំបន់រូងជានាង នៅចំណុចកំពស់ ៧១១ម៉ែត្រ ចំណុច **X0359707 & Y1290252** ភ្នំខ្នងស្រស់ ភូមិទំពាំងឃ្លៃ ឃុំប្រឡាយថ្មបាំង ខេត្តកោះកុង
- ចំនុចល្អាងស្ពាន ភ្នំទាក់ទ្រាំង ស្រុករតនមណ្ឌល ខេត្តបាត់ដំបង ។

អាជ្ញាធរខេត្តពាក់ព័ន្ធក្នុងប្រការនេះត្រូវផ្តល់របាយការណ៍អំពីវិធានការ និងលទ្ធផលការងាររបស់ខ្លួនតាមរយៈខ្សែទឹង និងខ្សែបណ្តោយមករាជរដ្ឋាភិបាលឱ្យបានជាប្រចាំ ។

៤_រាជរដ្ឋាភិបាលសូមធ្វើការអំពាវនាវដល់ជនរួមជាតិទាំងអស់ដែលបាន និងកំពុងប្រកបរបរទទួលទាន ជីកកកាយវត្ថុបុរាណដោយភ្លេចខ្លួន និងមិនស្របច្បាប់ មេត្តាបញ្ឈប់ជាបន្ទាន់នូវសកម្មភាព ដែលជាទង្វើខុសឆ្គងទាំងនោះ ព្រោះអាចនាំទៅភាពផុតរលត់នៃមរតកវប្បធម៌ជាតិ។

៥_ឈរលើស្មារតីភ្ញាក់រលឹកទាន់ពេលវេលា ជនរួមជាតិទាំងឡាយណាដែលបាន និងកំពុងកាន់កាប់ រាល់វត្ថុបុរាណទាំងអស់ មេត្តាបង្វែរប្រគល់ជូនរាជរដ្ឋាភិបាលវិញតាមរយៈអាជ្ញាធរដែនដី នៅនឹងកន្លែង ឬតាមសារមន្ទីរដែលនៅជិតខ្លួន ដើម្បីបញ្ជូនមករក្សាទុកឱ្យបានគង់វង្ស ។ មន្ត្រីអាជ្ញាធរដែលទទួលវត្ថុបុរាណអំពីដៃប្រជាជនត្រូវធ្វើកំណត់ហេតុទទួលវត្ថុបុរាណ ហើយបញ្ជូនកំណត់ហេតុមកអាជ្ញាធរខេត្ត ដើម្បីរាជរដ្ឋាភិបាលចាត់វិធានការផ្តល់ជូនវិញនូវការលើកទឹកចិត្ត សមស្របដល់សម្បុរសជនទាំងនោះឱ្យបានឆាប់រហ័សបំផុត ។

៦_អាជ្ញាធរជាតិទេសចរណ៍កម្ពុជា ត្រូវសម្របសម្រួលបង្កើតក្រុមការងារដែលមានសមាសភាពមកពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងមហាផ្ទៃ ក្រសួងទេសចរណ៍ អាជ្ញាធរអប្សរា និងស្ថាប័នពាក់ព័ន្ធ ដើម្បីពិភាក្សារិះរកមធ្យោបាយផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្តនេះ ធ្វើយ៉ាងណាឱ្យបានឆាប់រហ័សបំផុត ។

៧_រាជរដ្ឋាភិបាលនឹងទុករយៈពេលប្រាំមួយខែ ជូនដល់ជនរួមជាតិទាំងអស់ ដែលកំពុងបន្តកាន់កាប់វត្ថុបុរាណ វត្ថុជាទីសក្ការៈនៃប្រជាជន ចាប់ពីថ្ងៃប្រកាសដំណឹងតទៅ ត្រូវធ្វើការបង្វែរជូនរាជរដ្ឋាភិបាលវិញឱ្យទាន់ពេលវេលា ។ ជនណារឹងរូសដែលនៅតែបន្តគាស់បំផ្លាញប្រព្រឹត្តល្មើស និងមិនព្រមប្រគល់វត្ថុទាំងនោះមកថែរក្សាក្នុងសារមន្ទីរវិញទេ ជននោះនឹងត្រូវផ្តន្ទាទោសតាមបទប្បញ្ញត្តិ ដែលមានចែងក្នុងច្បាប់ស្តីពី កិច្ចការពារបេតិកភ័ណ្ឌវប្បធម៌ ។

ទទួលបានសារាចរណែនាំនេះគ្រប់ក្រសួង អាជ្ញាធរ ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី គ្រប់លំដាប់ថ្នាក់ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព ។

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែ មីនា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន
- គ្រប់សាលាខេត្ត-ក្រុង
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ......០៤...សរ.ពរ.ស

សេចក្តីអំពាវនាវ

របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការស្តារ និងរៀបចំកំណាត់ជងស្ទឹងសៀមរាប

-ព្រះតេជគុណ ព្រះសង្ឃគ្រប់ព្រះអង្គ ជាទីសក្ការៈ

-បងប្អូនអាជីវករ ពាណិជ្ជករ សេវាករ និង បងប្អូនប្រជាពលរដ្ឋទាំងអស់ជាទីគោរពស្រឡាញ់ !

វិស័យទេសចរណ៍កម្ពុជា គឺជាវិស័យអាទិភាព១ ក្នុងចំណោមវិស័យទាំង៦ សំរាប់ស្តារ និងអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ។ ជារៀងរាល់ឆ្នាំភ្ញៀវទេសចរ ដែលបានចូលមកទស្សនាកម្ពុជា មានការកើនឡើងជាលំដាប់ក្នុងចន្លោះពី ២៥ទៅ៣០% ហើយតាមការប៉ាន់ស្មានរបស់យើងក្នុងឆ្នាំ ២០០៣ ខាងមុខចំនួនភ្ញៀវទេសចរមកទស្សនាកម្ពុជាអាចនឹងកើនដល់ ១លាន នាក់ ហើយអាចនៅក្នុងអំឡុងឆ្នាំ ២០០៥ ខាងមុខ ភ្ញៀវទេសចរដែលមកទស្សនា **តំបន់ទេសចរណ៍សៀមរាបអង្គរ** អាចនឹងកើនដល់ ១លាន នាក់ ឬច្រើនជាងនេះ ។ ទន្ទឹមនឹងនោះ ចំនួនប្រជាពលរដ្ឋយើងក្នុងស្រុក ដែលធ្វើដំណើរកំសាន្តមកកាន់តំបន់នេះ ក៏កាន់តែមានការកើនឡើងយ៉ាងច្រើន ។ ទាំងអស់នេះបានបង្ហាញយ៉ាងច្បាស់ថា សន្តិភាព និងសន្តិសុខ បាន និងកំពុង គ្របដណ្តប់ទូទាំងប្រទេស ។ រាជរដ្ឋាភិបាលកម្ពុជា ដែលមានរូបខ្ញុំជាប្រមុខ នឹងខិតខំប្តូរផ្តាច់ ធ្វើអ្វីៗគ្រប់ បែបយ៉ាងដើម្បីថែរក្សាស្ថេរភាព សន្តិភាព សន្តិសុខ ឱ្យបានជារៀងរហូត ដើម្បីជាមូលដ្ឋានដល់ការអភិវឌ្ឍន៍ប្រទេសជាតិ និងជីវភាពរស់នៅដ៏សុខសាន្តរបស់ ប្រជាពលរដ្ឋ ។

ក្នុងអំឡុងប៉ុន្មានឆ្នាំកន្លងមក រាជរដ្ឋាភិបាល និងខ្លួនខ្ញុំផ្ទាល់បានខិតខំអស់ពីកំលាំងកាយចិត្ត ដើម្បីធ្វើការស្តារហេដ្ឋារចនាសម្ព័ន្ធមានជាអាទិ៍ ប្រព័ន្ធគមនាគមន៍ ស្ពាន ផ្លូវ អាកាសយានដ្ឋាន កំពង់ផែ ។ល។ ដោយឡែក នៅទីក្រុងសៀមរាបអង្គរនេះ អាកាសយានដ្ឋានកំពុងបន្តស្តារ និង អភិវឌ្ឍន៍ទៅមុខជានិច្ច ដើម្បីបញ្ចប់ដំណាក់កាលទី១ ក្នុងចំណោមដំណាក់កាលទាំង៤ ផ្លូវថ្នល់ក្នុងក្រុងបានស្តារ និងជួសជុលជាបន្តបន្ទាប់ ផ្លូវថ្នល់ទៅភ្នំក្រោមក៏កំពុងស្តារ និងស្ថាបនា ភ្លើងអគ្គីសនីបំភ្លឺផ្លូវក៏នឹងរៀបចំដាក់ជាបណ្តើរៗ ។ល។ ក្នុងនោះដងស្ទឹងសៀមរាប ដែលកាលពីប្រវត្តិសាស្ត្រដ៏យូរលង់គឺ ជាផ្លូវទឹកយ៉ាងសំខាន់បំរើឱ្យការដឹកជញ្ជូនថ្មាំងសិលាមកកសាងប្រាសាទនានានៅតំបន់អង្គរនោះ ក៏បានស្ថិតក្នុងផែនការស្តារ និងរៀបចំឡើងវិញ ឱ្យបានល្អ រួមចំណែកដល់ការកំសាន្តរបស់ភ្ញៀវទេសចរ និងកសាងសោភ័ណភាពដល់ទីក្រុងសៀមរាបអង្គរផងដែរ ។ ប៉ុន្តែដោយរាជរដ្ឋា

ភិបាលមានបន្ទុកធ្ងន់ធ្ងរជាច្រើន ដែលត្រូវរែកពន់លទ្ធភាពថវិកានៅមានកំរិត ពុំអាចដោះស្រាយសំណូមពរ នៃការអភិវឌ្ឍន៍លើគ្រប់វិស័យបានតែក្នុងមួយរយៈពេលខ្លីនោះ ក្នុងនាមរាជរដ្ឋាភិបាល និងក្នុងនាមខ្ញុំផ្ទាល់ ខ្ញុំសូមអំពាវនាវដល់ ព្រះតេជគុណ ព្រះសង្ឃគ្រប់ព្រះអង្គ បងប្អូនអាជីវករ ពាណិជ្ជករ សេវាករ បងប្អូនប្រជាពលរដ្ឋទាំងអស់នៅក្នុងខេត្ត សៀមរាប មេត្តាចូលរួមវិភាគទានតាមសទ្ធាជ្រះថ្លា ក្នុងការស្តារ និងកសាងផងស្ទឹងសៀមរាបនេះ ឱ្យបានច្រើនកុះករ និងសូមជួយថែរក្សាអនាម័យបរិស្ថាន តាមដងស្ទឹងឱ្យបានល្អ។

ខ្ញុំសូមឆ្លៀតឱកាសនេះ ថ្លែងអំណរគុណជាអនេកចំពោះបងប្អូនអាជីវករ សេវាករ ពាណិជ្ជករ ដែលជាម្ចាស់សណ្ឋាគារ ក្រុមហ៊ុនអាកាសចរ ដែលបានចូលរួមវិភាគទានដ៏ថ្លៃថ្លា តាមការអំពាវនាវរបស់រាជរដ្ឋាភិបាលកាលពីថ្ងៃទី ២៧ កុម្ភៈ ឆ្នាំ២០០២ កន្លងមកថ្មីៗនេះ ។

ជាថ្មីម្តងទៀត តាងនាមរាជរដ្ឋាភិបាល និងក្នុងនាមខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណ និងសូមសំដែងនូវសេចក្តីសង្ឃឹមជឿជាក់ដ៏ស្មោះសបំផុតចំពោះព្រះតេជគុណ ព្រះសង្ឃគ្រប់ព្រះអង្គ បងប្អូនអាជីវករ សេវាករ និងពាណិជ្ជករ ប្រជាពលរដ្ឋយើងទាំងអស់ និងសូមប្រគេនពរ និងជូនពរ សូមបានប្រកបដោយសុខភាពល្អ និងជោគជ័យគ្រប់ប្រការ ។

- គ្រប់វិភាគទានទាំងអស់ សូមមេត្តាទាក់ទងជាមួយលេខាធិការដ្ឋានរបស់គណៈកម្មការស្តារ និងអភិវឌ្ឍន៍កំណាត់ដងស្ទឹងនេះ ដែលមាន ឯកឧត្តម អ៊ឹម ឈុនលឹម រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាប្រធាន តាមទូរស័ព្ទលេខ ០១២ ៨០៨២៥៤, ០១២ ៩៩៨៩៩៨ *គ្រប់ពេលវេលា ។*

សូមអរព្រះគុណ និងសូមអរគុណ !

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែមីនា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ២៤០ សហវ.ថហ

រាជធានីភ្នំពេញ , ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០០២

ប្រកាស

ស្តីពីការផ្ទេរឥណទាន

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ , ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ១១/នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០១/១៥ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០២
- បានឃើញអនុក្រិត្យ លេខ ០៣ អនក្រ.បក , ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២ ស្តីពីការបែងចែកឥណទានថវិកាចំណាយ តាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២
- បានឃើញអនុក្រិត្យ លេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២ ស្តីពីការផ្ទេរឥណទានថវិកា
- បានឃើញប្រកាស លេខ ០១ ប្រ.សហវ , ចុះថ្ងៃទី ០៧ ខែ មករា ឆ្នាំ ១៩៩៤ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីចំណាត់ថ្នាក់ ចំណូល ចំណាយថវិកា តាមប្រភេទជំពូក ប្រការ កថាខ័ណ្ឌ វាក្យខ័ណ្ឌ នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការ គ្រប់គ្រង ឆ្នាំ ១៩៩៤
- បានឃើញប្រកាសលេខ ០០២ សហវ.ថហ.ប្រក , ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២ ស្តីពីការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងតាមប្រការ កថាខ័ណ្ឌ វាក្យខ័ណ្ឌ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២
- តាមសំណើរបស់ក្រសួងអប់រំ យុវជន និង កីឡា លេខ ១៤៨ អយក.ហវ,ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០២

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

សំរេច

ប្រការ១: ត្រូវបានប្រតិបត្តិនៅក្នុងវង្វង់ថវិការបស់ក្រសួងអប់រំ យុវជន និង កីឡា ផ្នែក ឧត្តមសិក្សា សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២ នូវការផ្ទេរឥណទាន ទៅអោយមន្ទីរអប់រំ យុវជន និង កីឡា ខេត្ត-ក្រុងទាំង ៧ (សំរាប់មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ) ដូចមានបញ្ជាក់ខាង ក្រោមនេះ :

ឯកតា : ពាន់រៀល

ជំពូក	ប្រការ	កថាខ័ណ្ឌ	វាក្យខ័ណ្ឌ	ចំណាត់ថ្នាក់ចំណាយ	ស្ថានភាពឥណទានដើមឆ្នាំ	ការកែប្រែឥណទាន កើន	ការកែប្រែឥណទាន ថយ	ស្ថានភាពឥណទានថ្មី
				សរុប ការផ្ទេរឥណទានរបស់ ក្រសួង អប់រំ យុវជន និង កីឡា ផ្នែកឧត្តមសិក្សា			867.000	
				-ជំពូក ១០			308.000	
10	02	03	02	ប្រាក់បំណាច់ម៉ោងបន្ថែម	1.074.000	-	304.000	770.000
10	03	01		បៀវត្សមូលដ្ឋានបុគ្គលិកអណ្តែត	14.000	-	4.000	10.000
				-ជំពូក ១១			272.000	
11	01	01	02	ការរៀបចំ និង ថែទាំ	280.000	-	23.000	257.000
11	01	01	04	អគ្គីសនី	1.000.000	-	29.000	971.000
11	01	02		ចលនៈវត្ថុ និង សំភារៈ	220.000	-	18.000	202.000
11	01	04		ក្រដាសបោះពុម្ព និង សំភារៈការិយាល័យ	190.000	-	23.000	167.000
11	01	07	01	ការថែទាំ និង ដំណើរការ	60.000	-	2.000	58.000
11	01	07	02	ប្រេងឥន្ធនៈ និង ប្រេងរំអិល	80.000	-	21.000	59.000
11	01	12	02	សំភារៈមន្ទីរពិសោធន៍ និង សំភារៈបច្ចេកទេសតូចតាចប្រើប្រាស់ជាប្រចាំ	100.000	-	6.000	94.000
11	01	14	05	ការប្រកួត និង សំភារៈកីឡា	15.000	-	7.000	8.000
11	02	01	01	សោហ៊ុយដឹកជញ្ជូនក្នុងប្រទេស	190.000	-	143.000	47.000
				-ជំពូក ៣១			287.000	
31	01	02	05	អាហារូបករណ៍ផ្សេងៗទៀត	450.000	-	287.000	163.000
				ផលប្រយោជន៍របស់មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត-ក្រុងទាំង ៧ (មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ)		867.000		
				១- ខេត្តស្ទឹងត្រែង		54.000		
				- ជំពូក ១០		22.000		
10	02	03	02	ប្រាក់បំណាច់ម៉ោងបន្ថែម	52.500	20.000	-	72.500
10	03	01		បៀវត្សមូលដ្ឋានបុគ្គលិកអណ្តែត	2.300	2.000	-	4.300
				- ជំពូក ១១		10.000		
11	01	01	02	ការរៀបចំ និង ថែទាំ	85.000	2.000	-	87.000
11	01	02		ចលនៈវត្ថុ និង សំភារៈ	20.000	1.000	-	21.000
11	01	04		ក្រដាសបោះពុម្ព និង សំភារៈការិយាល័យ	50.000	2.000	-	52.000

11	01	07	01	ការថែទាំ និង ដំណើរការ	11.000	1.000	-	12.000
11	01	07	02	ប្រេងឥន្ធនៈ និង ប្រេងរំអិល	41.000	3.000	-	44.000
11	01	14	05	ការប្រកួត និង សំភារៈកីឡា	0	1.000	-	1.000
				- ជំពូក ៣១		22.000		
31	01	02	05	អាហារូបករណ៍ផ្សេងៗទៀត	0	22.000	-	22.000
				២. ខេត្តតាកែវ		124.000		
				- ជំពូក ១០		60.000		
10	02	03	02	ប្រាក់បំណាច់ម៉ោងបន្ថែម	1.651.900	60.000	-	1.711.900
				- ជំពូក ១១		16.000		
11	01	01	02	ការរៀបចំ និង ថែទាំ	50.000	4.000	-	54.000
11	01	02		ចលនវត្ថុ និង សំភារៈ	36.800	3.000	-	39.800
11	01	04		ក្រដាសបោះពុម្ព និង សំភារៈការិយាល័យ	258.400	4.000	-	262.400
11	01	07	02	ប្រេងឥន្ធនៈ និង ប្រេងរំអិល	178.800	3.000	-	181.800
11	01	12	02	សំភារៈមន្ទីរពិសោធន៍ និង សំភារៈបច្ចេកទេសតូចតាចប្រើប្រាស់ជាប្រចាំ	0	1.000	-	1.000
11	01	14	05	ការប្រកួត និង សំភារៈកីឡា	0	1.000	-	1.000
				- ជំពូក ៣១		48.000		
31	01	02	05	អាហារូបករណ៍ផ្សេងៗទៀត	0	48.000	-	48.000
				៣. ខេត្តកំពង់ចាម		85.000		
				- ជំពូក ១០		30.000		
10	02	03	02	ប្រាក់បំណាច់ម៉ោងបន្ថែម	1.910.000	30.000	-	1.940.000
				- ជំពូក ១១		14.000		
11	01	01	02	ការរៀបចំ និង ថែទាំ	100.000	3.000	-	103.000
11	01	02		ចលនវត្ថុ និង សំភារៈ	100.000	2.000	-	102.000
11	01	04		ក្រដាសបោះពុម្ព និង សំភារៈការិយាល័យ	80.000	3.000	-	83.000
11	01	07	01	ការថែទាំ និង ដំណើរការ	15.000	1.000	-	16.000
11	01	07	02	ប្រេងឥន្ធនៈ និង ប្រេងរំអិល	70.000	3.000	-	73.000
11	01	12	02	សំភារៈមន្ទីរពិសោធន៍ និង សំភារៈបច្ចេកទេសតូចតាចប្រើប្រាស់ជាប្រចាំ	0	1.000	-	1.000
11	01	14	05	ការប្រកួត និង សំភារៈកីឡា	40.000	1.000	-	41.000
				- ជំពូក ៣១		41.000		
31	01	02	05	អាហារូបករណ៍ផ្សេងៗទៀត	0	41.000	-	41.000
				៤. ខេត្តព្រៃវែង		94.000		
				- ជំពូក ១០		52.000		
10	02	03	02	ប្រាក់បំណាច់ម៉ោងបន្ថែម	1.769.700	52.000	-	1.821.700
				- ជំពូក ១១		13.000		
11	01	01	02	ការរៀបចំ និង ថែទាំ	290.000	3.000	-	293.000
11	01	02		ចលនវត្ថុ និង សំភារៈ	533.800	2.000	-	535.800
11	01	04		ក្រដាសបោះពុម្ព និង សំភារៈការិយាល័យ	226.000	3.000	-	229.000
11	01	07	02	ប្រេងឥន្ធនៈ និង ប្រេងរំអិល	65.900	3.000	-	68.900

11	01	12	02	សំភារៈមន្ទីរពិសោធន៍ និង សំភារៈបច្ចេកទេសតូចតាចប្រើប្រាស់ជាប្រចាំ	8.500	1.000	-	9.500
11	01	14	05	ការប្រកួត និង សំភារៈកីឡា	50.000	1.000	-	51.000
				- ជំពូក ៣១		29.000		
31	01	02	05	អាហារូបករណ៍ផ្សេងៗទៀត	28.500	29.000	-	57.500
				៥. ខេត្ត បាត់ដំបង		159.000		
				- ជំពូក ១០		55.000		
10	02	03	02	ប្រាក់បំណាច់ម៉ោងបន្ថែម	1.687.000	55.000	-	1.742.000
				- ជំពូក ១១		46.000		
11	01	01	02	ការរៀបចំ និង ថែទាំ	248.000	4.000	-	252.000
11	01	01	04	អគ្គិសនី	60.000	29.000	-	89.000
11	01	02		ចលនវត្ថុ និង សំភារៈ	200.000	4.000	-	204.000
11	01	04		ក្រដាសបោះពុម្ព និង សំភារៈការិយាល័យ	200.000	4.000	-	204.000
11	01	07	02	ប្រេងឥន្ធនៈ និង ប្រេងរំអិល	88.000	3.000	-	91.000
11	01	12	02	សំភារៈមន្ទីរពិសោធន៍ និង សំភារៈបច្ចេកទេសតូចតាចប្រើប្រាស់ជាប្រចាំ	0	1.000	-	1.000
11	01	14	05	ការប្រកួត និង សំភារៈកីឡា	0	1.000	-	1.000
				- ជំពូក ៣១		58.000		
31	01	02	05	អាហារូបករណ៍ផ្សេងៗទៀត	0	58.000	-	58.000
				៦. ខេត្ត កណ្ដាល		75.000		
				- ជំពូក ១០		25.000		
10	02	03	02	ប្រាក់បំណាច់ម៉ោងបន្ថែម	2.434.000	23.000	-	2.457.000
10	03	01		បៀវត្សឈ្នួលផ្ទាល់បុគ្គលិកអណ្ដែត	0	2.000	-	2.000
				- ជំពូក ១១		13.000		
11	01	01	02	ការរៀបចំ និង ថែទាំ	149.200	3.000	-	152.200
11	01	02		ចលនវត្ថុ និង សំភារៈ	127.000	2.000	-	129.000
11	01	04		ក្រដាសបោះពុម្ព និង សំភារៈការិយាល័យ	342.800	3.000	-	345.800
11	01	07	02	ប្រេងឥន្ធនៈ និង ប្រេងរំអិល	249.300	3.000	-	252.300
11	01	12	02	សំភារៈមន្ទីរពិសោធន៍ និង សំភារៈបច្ចេកទេសតូចតាចប្រើប្រាស់ជាប្រចាំ	0	1.000	-	1.000
11	01	14	05	ការប្រកួត និង សំភារៈកីឡា	0	1.000	-	1.000
				- ជំពូក ៣១		37.000		
31	01	02	05	អាហារូបករណ៍ផ្សេងៗទៀត	0	37.000	-	37.000
				៧. រាជធានីភ្នំពេញ		276.000		
				- ជំពូក ១០		64.000		
10	02	03	02	ប្រាក់បំណាច់ម៉ោងបន្ថែម	1.350.000	64.000	-	1.414.000
				- ជំពូក ១១		160.000		
11	01	01	02	ការរៀបចំ និង ថែទាំ	655.000	4.000	-	659.000
11	01	02		ចលនវត្ថុ និង សំភារៈ	470.000	4.000	-	474.000
11	01	04		ក្រដាសបោះពុម្ព និង សំភារៈការិយាល័យ	200.000	4.000	-	204.000

11	01	07	02	ប្រេងឥន្ធនៈ និង ប្រេងរំអិល	200.000	3.000	-	203.000
11	01	12	02	សំភារៈមន្ទីរពិសោធន៍ និង សំភារៈបច្ចេកទេសតូចតាចប្រើប្រាស់ជាប្រចាំ	0	1.000	-	1.000
11	01	14	05	ការប្រកួត និង សំភារៈកីឡា	160.000	1.000	-	161.000
11	02	01	01	សោហ៊ុយដឹកជញ្ជូនក្នុងប្រទេស	0	143.000	-	143.000
				_- ជំពូក ៣១_		**52.000**		
31	01	02	05	អាហារូបករណ៍ផ្សេងៗទៀត	28.000	52.000	-	80.000

<u>ប្រការ២</u>: ឥណទានដែលបានផ្ទេរក្នុងប្រការ១ខាងលើនេះ ត្រូវបានបំពេញបន្ថែមនៅក្នុងសៀវភៅថវិការបស់មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត-ក្រុង ទាំង ៧ (មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ) សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២ សំរាប់ប្រាក់បំណាច់ម៉ោងបន្ថែម និង បៀវត្សមូលដ្ឋានបុគ្គលិកអណ្តែត , ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច និង អាហារូបករណ៍ផ្សេងៗទៀត ។

<u>ប្រការ៣</u>: ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា ឯកឧត្តមអភិបាលខេត្ត-ក្រុង ទាំង ៧ ជាអ្នកទទួលបន្ទុកអនុវត្ត ប្រកាស នេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ឆ.ស រដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

រដ្ឋលេខាធិការ

អ៊ុក រ៉ាប៊ុន

<u>ចំលងជូន</u>

- ក្រសួងអប់រំ យុវជន និង កីឡា
- នាយកដ្ឋានថវិកានីយកម្ម និង ហិរញ្ញកិច្ច
  (មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ)
- អង្គភាពយុទ្ធសាស្ត្រ និង គ្រប់គ្រងការអនុវត្តថវិកា (BSEC)
- រតនាគារជាតិ
- សាលាខេត្ត-ក្រុង ទាំង ៧
- រតនាគារ ខេត្ត-ក្រុង ទាំង ៧
- មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ខេត្ត-ក្រុង ទាំង ៧
- មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត-ក្រុង ទាំង ៧
  (មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ)

" ដើម្បីអនុវត្ត "

- កាលប្បវត្តិ - ឯកសារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ ថ្ងៃទី២៧ខែមីនា ឆ្នាំ ២០០២

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ២៤១ សហវ.ចហ

ប្រកាសអន្តរក្រសួង
ស្តីពី
ការតែងតាំងគ្នាក់ងារបើកផ្តល់ សំរាប់បើកប្រាក់បៀវត្សរ៍ និង ប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ ជូនមន្ត្រីរាជការ នៅក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

====

·ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
·ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុវរ្ម័នព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាលេខ ន.ស.រ.ក.ត១១៩៨/៧២ ចុះថ្ងៃ ទី ៣០ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រមលេខ ០៩ ន.ស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រពន្ធ័ហិរញ្ញវត្ថុ ហើយមានការកែប្រែក្នុងច្បាប់ស្តីពី ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ ន.ស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ហិរញ្ញវត្ថុសំរាប់គ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ នស.រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០១/១៥ ចុះថ្ងៃ ទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើ ច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០២
- បានឃើញអនុក្រឹត្យលេខ ៨២ អ.ន.ក្រ.ប.ក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាជាទូទៅនៃគណនេយ្យនៃសាធារណៈ
- បានឃើញប្រកាសលេខ ០០៤ សហវ.ថប្រក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញលិខិតលេខ ១១៥ សហវ.ម ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញតំរូវការចាំបាច់ នៃការងារសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបច្ចុប្បន្ន

សំរេច

ប្រការ១ : ប្រាក់បៀវត្សរ៍មន្ត្រីរាជការ នៃ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និង ប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ ត្រូវបើកផ្តល់តាមរយៈ " ភ្នាក់ងារបើកផ្តល់ " ។

ប្រការ២ : លោក អ៊ុម ហេន ត្រូវបានតែងតាំងជា ភ្នាក់ងារបើកផ្តល់ នៅក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ជំនួសលោក គៀត សត្ថារ៉ាទី ដែលត្រូវទៅបំពេញការងារនៅស្ថានទូតកម្ពុជាប្រចាំសាធារណរដ្ឋបារាំង និងលោក ម៉ែន ខណ្ណារ ជាភ្នាក់ងារបើកផ្តល់ជំនួស ។

ប្រការ៣ : លោក អ៊ុម ហេន និង លោក ម៉ែន ខណ្ណារ ត្រូវបានអនុញ្ញាតិអោយបើកគណនីប្រាក់បញ្ញើ នៅរតនាគារជាតិដើម្បី ទទួលមូលនិធិសំរាប់យកទៅបើកបៀវត្សរ៍ និងប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និងវប្បធម៌ជូនមន្ត្រីរាជការ

ប្រការ៤ : បែបបទនៃការអនុវត្តន៍ បើកផ្តល់បៀវត្ស និង ត្រូវកំណត់ដោយសេចក្តីណែនាំជាក្រោយ

ប្រការ៥ : ភ្នាក់ងារបើកផ្តល់ត្រូវទទួលខុសត្រូវផ្ទាល់ចំពោះប្រាក់កាស និង មូលនិធិដែលបានទទួលដើម្បីយកទៅធ្វើការបើកផ្តល់ជូនមន្ត្រីរាជការ

ប្រការ៦ : សេចក្តីសំរេចទាំងឡាយណា ដែលផ្ទុយនិងប្រកាសនេះត្រូវទុកជានិរាករណ៍

ប្រការ៧ : អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានរដ្ឋបាល ហិរញ្ញវត្ថុ ប្រធានរតនាគារជាតិ ប្រធាននាយកដ្ឋាន ព្រមទាំងប្រធានគ្រប់អង្គភាពពាក់ពន្ធ័ទាំងអស់ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិព្រមទាំងលោក អ៊ុម ហេន និង លោក ម៉ែន ខណ្ណារ ត្រូវទទួលបន្ទុកអនុវត្តន៍តាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

ហោ ណាំហុង

កន្លែងទទួល :

-ខុទ្ទកាល័យ សម្តេច នាយករដ្ឋមន្ត្រី

-ទីស្តីការគណៈរដ្ឋមន្ត្រី

" ដើម្បីជូនជ្រាប "

-ដូចប្រការ ៧ " ដើម្បីមុខការ "

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ២៤២ សហវ

រាជធានីភ្នំពេញ ថ្ងៃទី២៨ខែ មិនា ឆ្នាំ ២០០២

ប្រកាស
ស្តីពី
ការបោះផ្សាយសញ្ញាប័ណ្ណរដ្ឋ ដើម្បីបំពេញដើមទុនអោយ ក្រុមហ៊ុនជាតិធានារ៉ាប់រងកម្ពុជា «កាមិនកូ»

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម លេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០០/០២ ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការធានារ៉ាប់រង
- បានឃើញព្រះរាជក្រម លេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ហើយត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រម នស/រកម/១២០១/១៥ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០២
- បានឃើញអនុក្រឹត្យ លេខ ១០៦ អនក្រ ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០១ ស្តីពី ការធានារ៉ាប់រង
- បានឃើញអនុក្រឹត្យ លេខ ១៣២ អនក្រ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពី ការបង្កើតក្រុមហ៊ុនជាតិធានារ៉ាប់រងកម្ពុជា «កាមិនកូ»ៗ

សម្រេច

ប្រការ ១-

បោះផ្សាយសញ្ញាប័ណ្ណរដ្ឋ សំរាប់បំពេញដើមទុនអោយក្រុមហ៊ុនជាតិធានារ៉ាប់រងកម្ពុជា «កាមិនកូ» ក្នុងកំរិតទឹកប្រាក់ចំនួន ២៣.០០០.០០០.០០០៛(ម្ភៃបីពាន់លានរៀល) ដើម្បីបង្គ្រប់ចំនួន ២៨.០០០.០០០.០០០៛ (ម្ភៃប្រាំបីពាន់លានរៀល) ។ ទន្ទឹមគ្នានេះដែរ ក្រុមហ៊ុនកាមិនកូ ត្រូវផ្តល់នូវប័ណ្ណភាគហ៊ុនរបស់ខ្លួនមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានទឹកប្រាក់សរុបស្មើ ២៨.០០០.០០០.០០០៛ (ម្ភៃប្រាំបីពាន់លានរៀល) ដែលក្នុងនោះមាន ២៨០.០០០ ប័ណ្ណភាគហ៊ុន (ពីររយប៉ែតសិបពាន់ប័ណ្ណភាគហ៊ុន) និងមានតម្លៃនាមចារឹកក្នុងមួយឯកតា ១០០.០០០៛ (មួយរយពាន់រៀល) ។

ប្រការ ២-

សញ្ញាប័ណ្ណរដ្ឋត្រូវបានបោះផ្សាយនៅថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០២ ចំនួន ២.៣០០ ប័ណ្ណ (ពីរពាន់បីរយប័ណ្ណ) ដោយមានតម្លៃនាមចារឹក ក្នុងមួយឯកតា ១០.០០០.០០០ ៛ (ដប់លានរៀល) ។

ប្រការ ៣-

សញ្ញាប័ណ្ណរដ្ឋត្រូវបានបោះផ្សាយសំរាប់រយៈពេល ០៣ ឆ្នាំ (បីឆ្នាំ) តាមឥណប្រតិទានកំណត់ក្នុងសញ្ញាប័ណ្ណ ។ ក្នុងរយៈពេលបីឆ្នាំនេះ អ្នកកាន់សញ្ញាប័ណ្ណ នឹងត្រូវបានទទួលការប្រាក់ប្រចាំឆ្នាំចំនួន ៣% (បីភាគរយ) ហើយការទូទាត់ការប្រាក់នេះត្រូវធ្វើឡើងជារៀងរាល់ ០៦ ខែ (ប្រាំមួយខែ) ម្តង ដោយឈរលើមូលដ្ឋាន ០៦ ខែ ស្មើ ១៨០ ថ្ងៃ និង មួយឆ្នាំ ស្មើ ៣៦០ ថ្ងៃ ។

ប្រការ ៤-

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានសិទ្ធធ្វើសំណងសញ្ញាប័ណ្ណរដ្ឋមុនឥណប្រតិទាន ដែលបានកំណត់ក្នុងសញ្ញាប័ណ្ណ គឺអាស្រ័យដោយស្ថានភាពថវិការបស់រដ្ឋ ។

ប្រការ ៥-

នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ទទួលបន្ទុកតាមដានរាល់ស្ថានភាពបំណុលនៃសញ្ញាប័ណ្ណរដ្ឋព្រមទាំងធ្វើរបាយការណ៍ជូននាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ (ការិយាល័យគ្រប់គ្រងបំណុល) ។

ប្រការ ៦-

ប្រកាសនេះមានប្រសិទ្ធភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

ចម្លងជូន

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមហ៊ុនជាតិធានារ៉ាប់រងកម្ពុជា- ឯកសារ- កាលប្បវត្តិ

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ មិនា ឆ្នាំ ២០០២

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ២៤៣ សហវ

ប្រកាស

ស្តីពី

ការបោះផ្សាយសញ្ញាប័ណ្ណរដ្ឋ ដើម្បីបំពេញដើមទុនអោយក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា «កម្ពុជា រី»

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម លេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០០/០២ ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការធានារ៉ាប់រង
- បានឃើញព្រះរាជក្រម លេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ហើយត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រម លេខ នស/រកម/១២០១/១៥ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០២
- បានឃើញអនុក្រឹត្យ លេខ ១០៦ អនក្រ ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០១ ស្តីពីការ ធានារ៉ាប់រង
- បានឃើញអនុក្រឹត្យ លេខ ០៧ អនក្រ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០០១ ស្តីពីការបង្កើតក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា «កម្ពុជា រី» ៥

សម្រេច

ប្រការ ១-

បោះផ្សាយសញ្ញាប័ណ្ណរដ្ឋ សំរាប់បំពេញដើមទុនអោយក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា «កម្ពុជា រី»ក្នុងកំរិតទឹកប្រាក់ចំនួន ២៧.៩០០.០០០.០០០៛ (ម្ភៃប្រាំពីរពាន់ប្រាំបួនរយលានរៀល) និងបន្ថែមជាសាច់ប្រាក់សុទ្ធចំនួន ១០០.០០០.០០០៛ (មួយរយលានរៀល) ដើម្បីអោយគ្រប់ចំនួន ២៨.០០០.០០០.០០០៛ ។ ទន្ទឹមគ្នានេះដែរក្រុមហ៊ុនកម្ពុជរី ត្រូវផ្តល់នូវប័ណ្ណភាគហ៊ុនរបស់ខ្លួនមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានទឹកប្រាក់សរុបស្មើ ២៨.០០០.០០០.០០០៛ (ម្ភៃប្រាំបីពាន់លានរៀល) ដែលក្នុងនោះមាន ២៨០.០០០ប័ណ្ណភាគហ៊ុន (ពីររយប៉ែតសិបពាន់ប័ណ្ណភាគហ៊ុន) និងមានតំលៃនាមករណ៍ក្នុងមួយឯកតា ១០០.០០០៛ (មួយរយពាន់រៀល) ។

ប្រការ ២-

សញ្ញាប័ណ្ណរដ្ឋត្រូវបានបោះផ្សាយនៅថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០២ ចំនួន ២.៧៩០ ប័ណ្ណ (ពីរពាន់ប្រាំពីររយកៅសិបប័ណ្ណ) ដែលមានតំលៃនាមករណ៍ក្នុងមួយឯកតា ១០.០០០.០០០៛ (ដប់លានរៀល) ។

ប្រការ ៣-

សញ្ញាប័ណ្ណរដ្ឋត្រូវបានបោះផ្សាយសំរាប់រយៈពេល ០៣ ឆ្នាំ (បីឆ្នាំ) តាមឥណប្រតិទានកំណត់ក្នុងសញ្ញាប័ណ្ណ ។ ក្នុងរយៈពេលបីឆ្នាំនេះ អ្នកកាន់សញ្ញាប័ណ្ណ នឹងត្រូវបានទទួលការប្រាក់ប្រចាំឆ្នាំចំនួន ៣% (បីភាគរយ) ហើយការទូទាត់ការប្រាក់នេះត្រូវធ្វើឡើងជារៀងរាល់ ០៦ ខែ (ប្រាំមួយខែ) ម្តង ដោយឈរលើមូលដ្ឋាន ០៦ ខែ ស្មើ ១៨០ ថ្ងៃ និង មួយឆ្នាំ ស្មើ ៣៦០ ថ្ងៃ ។

ប្រការ ៤-

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានសិទ្ធធ្វើសំណងសញ្ញាប័ណ្ណរដ្ឋមុនឥណប្រតិទានដែលបានកំណត់ក្នុងសញ្ញាប័ណ្ណ គឺអាស្រ័យដោយស្ថានភាពថវិការបស់រដ្ឋ ។

ប្រការ ៥-

នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ទទួលបន្ទុកតាមដានរាល់ស្ថានភាពបំណុលនៃសញ្ញាប័ណ្ណរដ្ឋ ព្រមទាំងធ្វើរបាយការណ៍ជូននាយកដ្ឋានវិនិយោគ និង សហប្រតិបត្តិការ (ការិយាល័យគ្រប់គ្រងបំណុល) ។

ប្រការ ៦-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

ចម្លងជូន
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ: 102 ប្រក.កសក

ប្រកាស

ស្ដីពី

ការបង្កើតចំការពូជឈើក្នុងព្រៃសហគមន៍សហគ្រាសកូឡិចស៊ីម ក្នុងប្លុកលេខ ៨ គុបលេខ IV-12 អនុតំបន់ IV នៅឃុំទីរង ស្រុកសណ្ដាន់ ខេត្តកំពង់ធំ

~~~~~~~~~~

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញក្រឹត្យ-ច្បាប់លេខ ៣៥ក្រ.ច ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៨៨ ស្ដីពីការគ្រប់គ្រងវិស័យព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- តាមសំណើរបស់ប្រធាននាយកដ្ឋាន រុក្ខា-ប្រមាញ់

សម្រេច

ប្រការ១ : បង្កើតចំការពូជឈើមួយកន្លែង មានផ្ទៃដីទំហំ **១១៧ ហិកតា** ដែលមានទីតាំងស្ថិតនៅ ប្លុកលេខ ៨ គុបលេខ IV-12 អនុតំបន់ IV ក្នុងព្រៃសម្បទានសហគ្រាសកូឡិចស៊ីម ក្នុងឃុំទីរង ស្រុកសណ្ដាន់ ខេត្តកំពង់ធំ ដើម្បីធ្វើការអភិរក្សធនធានសេនេទិច និង ធ្វើការប្រមូលគ្រាប់ពូជសំរាប់ផ្គត់ផ្គង់ដល់ការដាំឈើ និង ដាំឈើឡើងវិញរួមមាន ចំនួន ៦ ប្រភេទ គឺ : **ធ្នង់ថែម កកោះ ឈើទាល ផ្ដៀក លំបោរ និង ជ័រចុង ។**

ប្រការ២ : ការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ចំការពូជឈើនេះ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានរុក្ខា-ប្រមាញ់ (ការិយាល័យដាំឈើ)សហការជាមួយសហគ្រាសកូឡិចស៊ីម និង មានការបែងចែកទទួលភារកិច្ចដូចតទៅ :

-នាយកដ្ឋានរុក្ខា-ប្រមាញ់ (ការិយាល័យដាំឈើ) មានភារកិច្ចត្រួតពិនិត្យ តាមដានលើផ្នែកបច្ចេកទេសសេនេទិច និងរុក្ខវប្បកម្មនៃប្រភេទពូជឈើនីមួយៗ និង ធ្វើការប្រមូលគ្រាប់ពូជជារៀងរាល់ឆ្នាំ សំរាប់បំរើឱ្យការងារដាំឈើ និងដាំឈើឡើងវិញ ។
~~~~~~~~~~

-២-

-សហគ្រាសកូឡិចស៊ីម មានតួនាទីភារកិច្ចគ្រប់គ្រងថែរក្សា ការពារ បង្ការភ្លើងព្រៃ និង ចាត់វិធានការនូវគ្រប់រូបភាពអនាធិបតេយ្យក្នុងចំការពូជឈើនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់បំផុត។

ប្រការ៣ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ៤ : អគ្គនាយកនៃក្រសួង អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស ប្រធាននាយកដ្ឋានផែនការ-ស្ថិតិនិងសហប្រតិបត្តិការអន្តរជាតិ ប្រធាននាយកដ្ឋានរុក្ខា-ប្រមាញ់ ប្រធានសហគ្រាសកូឡិចស៊ីម និង ប្រធានមន្ទីរកសិកម្មរុក្ខា-ប្រមាញ់ និងនេសាទខេត្តកំពង់ធំ ត្រូវទទួលបន្ទុករៀងៗខ្លួនអនុវត្តប្រកាសនេះឱ្យទទួលបានប្រសិទ្ធិភាពខ្ពស់ ។

ប្រការ៥ : ប្រកាសនេះ មានអានុភាពគតិយុត្តិចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី 26 ខែ ០៤ ឆ្នាំ ២០០២

រដ្ឋមន្ត្រី

ច័ន្ទ-សារុន

កន្លែងទទួល:

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-ក្រសួងបរិស្ថាន

-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-សាលាខេត្តកំពង់ធំ

"ដើម្បីជូនជ្រាប"

-ដូចមានចែងក្នុងប្រការ៤

"ដើម្បីអនុវត្ត"

-ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ
បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

លេខ.....០.....៨.....៦........សកបយ

ភ្នំពេញ,ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០២

ប្រកាស

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត-១១៩៨-៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២-នស-៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស.រកម-០៣៩៧-០១ ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ១៩៩៧ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស-រកម-០៦៩៩-០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៩ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ-បក ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ១៩៩៩ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៥របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីការ បញ្ជូនពលករខ្មែរទៅធ្វើការនៅឯបរទេស

- បានឃើញកំហុសរបស់ក្រុមហ៊ុន ស៊ី ស៊ី អេ ចំកាត់ ស្តីពីការមិនបានអនុវត្តប្រការ៣នៃប្រកាស លេខ០៨០ សកបយ ចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០០១និងប្រការ៦នៃកិច្ចសន្យាស្តីពីការបញ្ជូនពលករខ្មែរទៅធ្វើការនៅប្រទេសក្រិច រវាងក្រសួងសង្គមកិច្ច ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា និងក្រុមហ៊ុន ស៊ី ស៊ី អេ ចំកាត់ ។

ស ម្រេ ច

ប្រការ ១: ត្រូវបានចាត់ទុកជានិរាករណ៍នូវប្រកាស លេខ ០៨០ សកបយ ចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០០១ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ស្តីពីការអនុញ្ញាតិឱ្យក្រុមហ៊ុន ស៊ី ស៊ី អេ ចំកាត់ C.C.A.Co., LTD (CAMBODIAN CONSULTANT ASSOCIATE) ធ្វើការបណ្តុះបណ្តាល និងបញ្ជូនពលករខ្មែរទៅធ្វើការនៅប្រទេសក្រិច ។

ប្រការ ២: មេដឹកនាំទាំងអស់របស់ក្រុមហ៊ុន ស៊ី ស៊ី អេ ចំកាត់ ត្រូវទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់នូវរាល់ការខូចខាតដែលក្រុមហ៊ុន ស៊ី ស៊ី អេ ចំកាត់ បានបង្កឡើង ។

ប្រការ ៣: បទប្បញ្ញត្តិទាំងឡាយ ដែលផ្ទុយទៅនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៤: អគ្គនាយដ្ឋានការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នាយកដ្ឋានមុខរបរ និងហត្ថពលកម្ម អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ និងខុទ្ទកាល័យត្រូវអនុវត្តប្រកាសនេះអោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

អ៊ិត សំហេង

ចម្លងជូន :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួងពាក់ព័ន្ធ
" ដើម្បីជូនជ្រាប "
-ដូចប្រការ ៤ " ដើម្បីអនុវត្ត "
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

លេខ ៧៤ វប.ក

ភ្នំពេញ,ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០០២

ប្រកាស

ស្តីពី

ការបង្កើតគណៈកម្មាធិការ កំណត់បុរេលក្ខណៈសម្បត្តិ វាយតំលៃ និង ប្រគល់កិច្ចសន្យាលទ្ធកម្ម (PEAC)

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស.រកម ០១៩៦ ០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើត ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
- បានឃើញអនុក្រិត្យលេខ២០ អនក្រ.បត ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រិត្យលេខ៦០អនក្រ.បក ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ ១៩៩៥ របស់រាជរដ្ឋាភិបាល ស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ
- បានឃើញប្រកាសលេខ៣១៩ កហវ.ប្រក ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ១៩៩៥ និងសេចក្តីណែនាំលេខ០០៦ សណន.សហវ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការអនុវត្តន៍ វិធាន និងបទបញ្ញត្តិក្នុងការគ្រប់គ្រងលទ្ធកម្ម សាធារណៈរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

សំរេច

ប្រការ១ : បង្កើតគណៈកម្មាធិការកំណត់បុរេលក្ខណៈសម្បត្តិវាយតម្លៃ និងប្រគល់កិច្ចសន្យាលទ្ធកម្មហៅកាត់ថាគណៈកម្មាធិការ (PEAC) នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដែលមានសមាសភាពដូចតទៅ:

១- អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ ប៉ាណារ៉ា ស៊ីរីវុឌ្ឍ ជាប្រធាន
២- ឯកឧត្តម ស៊ឹម សារ៉ាក់ ជាអនុប្រធាន
៣- លោក ចាស សារុន សមាជិក
៤- លោក អ៊ួង វន សមាជិក
៥- លោកស្រី លន់ សាឌី សមាជិក
៦- លោកស្រី ទេព សុនណារីម សមាជិក
៧- លោក ចំនួ វណ្ណា ប្រធាន PU សមាជិក-លេខាធិការ

ប្រការ២ : គណៈកម្មាធិការ PEAC មានភារកិច្ចដូចតទៅ :-

- កំណត់បុរេលក្ខណៈសម្បត្តិ នៃការផដេញថ្លៃទំនិញ-ការសាងសង់-សេវា
- វាយតំលៃលើសំណើដេញថ្លៃ-ពិគ្រោះថ្លៃ
- ផ្តល់អនុសាសន៍ថ្នាយ-ជូនប្រធានស្ថាប័ន ពិនិត្យសំរេច និងប្រគល់កិច្ចសន្យា
- មានសិទ្ធិកោះអញ្ជើញបណ្តាផ្នែកជំនាញ ក្រោមឱវាទដែលពាក់ព័ន្ធ និងចម្លងការលទ្ធកម្មមកបំភ្លឺ និងផ្តល់យោបល់ពីការងារបច្ចេកទេសក្នុងករណីចាំបាច់ ។

ប្រការ៣ : ខុទ្ទកាល័យ អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌ បណ្តាអង្គភាពពាក់ព័ន្ធ មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈគ្រប់ខេត្ត-ក្រុង អ្នកអង្គម្ចាស់ ឯកឧត្តម លោក លោកស្រី ដែលមានឈ្មោះ ដូចក្នុងប្រការ១ មានភារកិច្ចត្រូវអនុវត្តប្រកាសនេះ ។

ប្រការ៤ : ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្ត ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ហើយរាល់សេចក្តីសំរេចដែលមានពីមុន និងផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

[illegible]

ចម្លងជូន

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
  (ដើម្បីជូនជ្រាប)
- ដូចប្រការ១ និង៣
- ឯកសារ-កាលប្បវត្តិ